ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ រយៈពេល ៣ ឆ្នាំ (២០១៩ - ២០២១)

ឈ្មោះសហគមន៍នេសាទ ៖ បឹងវាម

ភូមិ ៖ ជើងដឹក ជីប្រាយ និងក្តីថ្ក

ឃុំ ៖ ប្រាំយ៉ាម

ស្រុក ៖ ស្រីសន្ធរ

ខេត្ត ៖ កំពង់ចាម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# រយៈពេល ៣ ឆ្នាំ
# (២០១៩ - ២០២១)

ឈ្មោះសហគមន៍នេសាទ ៖ បឹងភាម

ភូមិ ៖ ជើងដឹក ជីប្រាយ និងក្ដីថ្កូ

ឃុំ ៖ ប្រាំយ៉ាម

ស្រុក ៖ ស្រីសន្ធរ

ខេត្ត ៖ កំពង់ចាម

# មាតិកា

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១. ស្ថានភាពទូទៅ** ........ 1

**២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ........ 1

ក- ប្រជាសាស្ត្រ ........ 1

ខ- មុខរបរ ........ 2

**៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ 2

ក- ទីតាំង ........ 2

ខ- ដែននេសាទ ........ 2

គ- តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ 3

ឃ- ធនធានជលផល ........ 3

**៤. ការធ្វើនេសាទ** ........ 3

ក- អ្នកនេសាទ ........ 3

ខ- ឧបករណ៍នេសាទ ........ 4

គ- ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ ........ 5

**៥. ផែនការគ្រប់គ្រងសហគមន៍នេសាទ** ........ 5

ក- ទស្សនៈវិស័យ ........ 5

ខ- គោលបំណង ........ 5

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ 6

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ 6

គ២-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ 6

គ៣-ផែនការគ្រប់គ្រងព្រៃលិចទឹក ........ 7

គ៤-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល ........ 8

គ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ 8

គ៦-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ ........ 9

គ៧-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ 10

ឃ- ផែនការយុទ្ធសាស្ត្រ ........ 11

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងវាម រយៈពេល ៣ឆ្នាំ (២០១៩ដល់២០២១)** ........ 12

**តារាងកម្មវិធីការងារ** ........ 15

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទបឹងវាមបានរៀបចំមហាសន្និបាតកំណើតលើកដំបូង នៅថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០០៧ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

សហគមន៍នេសាទបឹងវាមមានទីតាំងស្ថិតនៅក្នុងភូមិជើងដឹក ដីប្រាយ ក្ដីក្ដ ឃុំប្រាំយ៉ាម ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម មានសមាជិកសហគមន៍នេសាទសរុបចំនួន១៣៧នាក់ មានប្រុសចំនួន១២៦ និងស្រីចំនួន១១នាក់ ក្នុងនោះ មានចំនួនគ្រួសារសរុប១៣៧គ្រួសារ ដែលមានគណៈកម្មការសហគមន៍នេសាទចំនួន០៧នាក់ ស្រីគ្មាន និងមានក្រុមល្បាតមួយក្រុម មាន១១នាក់។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន៖

- រៀបចំធ្វើមហាសន្និបាតបង្កើតសហគមន៍នេសាទ
- រៀបចំរចនាសម្ពន្ធគណៈកម្មការសហគមន៍នេសាទ និងបង្កើតក្រុមល្បាត
- រៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- កំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍
- រៀបចំធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ចុះល្បាត តាមដាន និងទប់ស្កាត់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍
- ស្នើសុំចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពគណកម្មការសហគមន៍នេសាទ
- ចូលរួមប្រជុំជាមួយអាជ្ញាធររដ្ឋបាលភូមិ ឃុំ
- ប្រមូលព័ត៌មានទូទៅសម្រាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក- ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទ៤៩៩០នាក់ ប្រុស២២៣១នាក់ ស្រី២៧៥៩នាក់ ក្នុងនោះ មានជនជាតិខ្មែរចំនួន៤៩៩០នាក់ ខ្មែរឥស្លាមគ្មាន និងអាណិកជនវៀតណាមគ្មាន។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១២០នាក់
- ចំនួនពោះម៉ាយក្នុងសហគមន៍នេសាទមាន២៨នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន១៦នាក់ ស្រី៦នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៤៣នាក់ ស្រី៣៣នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន១៥នាក់ ស្រី១២នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍មានអ្នកកាន់សាសនាព្រះពុទ្ធ១០០%។ ក្រៅពីនេះអ្នកកាន់សាសនាអ៊ីស្លាម 0% សាសនាកាតុលិក0%។

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន៨២នាក់ ស្រី៤៩នាក់ កម្រិតថ្នាក់បឋមសិក្សាមានចំនួន៥០៧នាក់ ស្រី១០៧នាក់ និងកម្រិតមធ្យមសិក្សាមានចំនួន២៧៩នាក់ ស្រី១៩៣នាក់ និងកម្រិតថ្នាក់ឧត្តមសិក្សាមានចំនួន៤៩នាក់ ស្រី៣៣នាក់ ។

ខ- មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- ធ្វើនេសាទចំនួន ២៣០គ្រួសារ
- ធ្វើស្រែចំនួន ៨០០គ្រួសារ ទំហំផ្ទៃដី ៧២២ហិកតា
- ធ្វើវារីវប្បកម្មចំនួន ០ គ្រួសារ ចំនួន ០ហិកតា
- ជាងផ្ទះចំនួន ៤គ្រួសារ
- ធ្វើចំការចំនួន គ្មាន
- ចិញ្ចឹមសត្វចំនួន ៦៩៨គ្រួសារ
- លក់ដូរចំនួន ៤៩គ្រួសារ
- កម្មករចំនួន ៧៤៦គ្រួសារ
- មន្ត្រីរាជការចំនួន ៤៧គ្រួសារ
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំ មានចំនួន ៥ ៤៧៥ ០០០រៀល

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

ក- ទីតាំង

កន្លែងនេសាទសហគមន៍បឹងវាម ជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីក្នុងដែននេសាទទឹកសាបមានទំហំ៦៨២ហិកតានិងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់និងឃុំផ្ទះកណ្តាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម
- ខាងត្បូងទល់និងឃុំប្រាំយ៉ាម ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម
- ខាងកើតទល់និងឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម
- ខាងលិចទល់និងឃុំខ្នារស ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

ខ- ដែននេសាទ

កន្លែងនេសាទសហគមន៍បឹងវាមមានបឹងចំនួន០១ មានទំនាបលិចទឹកក្នុងរដូវជំនឿងនិងនាទីព្រៃលិចទឹក ៖

- បឹងវាម មានទំហំប្រហែល ៦៤៥ហិកតា នេសាទពេញមួយឆ្នាំ
- ទំនាបលិចទឹកក្នុងរដូវជំនឿង និងនាទីព្រៃលិចទឹក មានទំហំប្រហែល ៣៧ហិកតា។

គ- តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

អន្លង់បឹងរាម មានទំហំ៦ហិកតា (បណ្ដោយ៣០០ម៉ែត្រ និងទទឹង២០០ម៉ែត្រ)។

ឃ- ធនធានជលផល

- ប្រភេទត្រី (ត្រីរ៉ស់ ត្រីឆ្ដោ ត្រីប្រា ត្រីពោ ត្រីឆ្លាំង ត្រីកែស ត្រីក្រម៉ម ត្រីតាអោន ត្រីក្អែក ត្រីក្រឡង់ ត្រីសណ្ដាយ ត្រីអណ្ដែង ត្រីដំរី ត្រីឆ្លូញ ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទឹង ត្រីកញ្ជនជ័យ ត្រីខ្មាន់ ត្រីឈ្វៀត ត្រីកញ្ជ្រូក ត្រីបណ្ដូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រាយ ត្រីខ្ទឹង ត្រីព្រួល ត្រីទ្រនេន ត្រីក្រសក់ ត្រីគល់រាំង ត្រីកន្ធ្រប ត្រីកន្ធ្របខ្លា ត្រីកញ្ចុះ ត្រីលិញ ត្រីក្រាញ់ ត្រីចង្វា ត្រីផ្ទោង ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីក្លាំងហាយ ត្រីកន្ធរ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្ដាម ត្រីលលកសរ ត្រីឆ្ពិន ត្រីបណ្ដូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស់ ត្រីកំភ្លាញ កំពឹស បង្កង,.....។ល។)
- ប្រភេទវារីសត្វ (ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ខ្ទៅ លៀស គ្រុំប៉ោក គ្រុំចំពុះទា ក្ដាម អន្ទង់ កង្កែប អណ្ដើក កន្ធាយ កេ,......។ល។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ (ដើមរាំង ភ្នំភ្លេង ប្របួយមេ ប្របួយឈ្មោល ថ្លើមអណ្ដើក អូយយ៉ាស់(បន្លាយយួន) អញ្ចាញ កន្សែង ស្នែងក្របី ស្នួលទឹក ច្រកែង ប្រផេញ ផ្ដៅ ត្អែកព្រាប បាក់ដង កន្សៀវ ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្ងាង ត្បូ ខ្នាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ ដោះគន់ វល្លិ៍ត្រី វល្លិ៍ត្អើក ល្ពាក់ទឹក ស្លាបទា កន្ទាំងហែ រញា ស្មៅ ស្លត់ បន្លាឃ្លេ ផ្ទោល ថ្ងាន់ ត្រដក់ កន្ទុយអន្ទង់ ពោះក្អម ត្រកួន ព្រលិតអាចមន៍មាន់ ព្រលិតដូង រំចង់ ស្ពន់អំបោះ ត្រាវអណ្ដែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំបួង កក់ជ្រុង កក់ក្ដាម ឈូក ចន្ទល់ភ្នំ(វល្លិ៍ថ្គាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ស្ពន់ដំរី វល្លិ៍អណ្ដាតត្រកួត ក្រចាប់ សារាយ កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ។ល។)

## ៤. ការធ្វើនេសាទ

ក- អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៨៥នាក់ ស្រី១០នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន ១៤៥នាក់ ស្រី២៣នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន១៥៥នាក់ ស្រី៦នាក់

ខ- ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូករបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៨៥ | ១៥០ម-២០០ម/គ្រួសារ | ១០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| អួនអូស | ម៉ែត្រ | ៣ | ១៥-២០ម៉ែត្រ/គ្រួសារ | ៦០ម៉ែត្រ | មករា-ឧសភា |
| សន្ទូចរនង | ផ្លែ | ២០ | ២០០-៣០០ផ្លែ/គ្រួសារ | ៦០០០ផ្លែ | ពេញមួយឆ្នាំ |
| លប | គ្រឿង | ១ | ៤០-៦០គ្រឿង/គ្រួសារ | ៦០គ្រឿង | ពេញមួយឆ្នាំ |
| លាន់ | គ្រឿង | ២ | ២០-៤០គ្រឿង/គ្រួសារ | ៨០គ្រឿង | វិច្ឆិកា-សីហា |
| សំណាញ់ | វង់ | ១០ | ១វង់/គ្រួសារ | ១០វង់ | វិច្ឆិកា-សីហា |
| ឈ្នាងជញ្ជាត់លៀស | គ្រឿង | ១ | ១គ្រឿង/គ្រួសារ | ១គ្រឿង | ធ្នូ-ឧសភា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ៨៥គ្រឿង | ១៥០-៣០០គីឡូក្រាម | ៤-៧សេះ |
| ទូកអុំ | គ្មាន | | |

- ឧបករណ៍នេសាទ និងទូករបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១០៥ | ១៥០ម-២០០ម/គ្រួសារ | ២១០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| អួនអូស | ម៉ែត្រ | ៥ | ១៥-២០ម៉ែត្រ/គ្រួសារ | ១០០ម៉ែត្រ | មករា-ឧសភា |
| សន្ទូចរនង | ផ្លែ | ៣៥ | ២០០-៣០០ផ្លែ/គ្រួសារ | ១០៥០០ផ្លែ | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១៥ | ១វង់/គ្រួសារ | ១៥វង់ | វិច្ឆិកា-សីហា |
| ឈ្នាងជញ្ជាត់លៀស | គ្រឿង | ៧ | ១គ្រឿង/គ្រួសារ | ៧គ្រឿង | ធ្នូ-ឧសភា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ៩០គ្រឿង | ១៥០-៣០០គីឡូក្រាម | ៤-៧សេះ |
| ទូកអុំ | គ្មាន | | |

- ឧបករណ៍នេសាទណនិងទូករបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១១០ | ១៥០ម-២០០ម/គ្រួសារ | ២២០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| អួនអូស | ម៉ែត្រ | ៥ | ១៥-២០ម៉ែត្រ/គ្រួសារ | ១០០ម៉ែត្រ | មករា-ឧសភា |

| | | | | | |
|---|---|---|---|---|---|
| សន្ទូចរនង | ផ្លែ | ២០ | ២០០-៣០០ផ្លែ/គ្រួសារ | ៦០០០ផ្លែ | ពេញមួយឆ្នាំ |
| លប | គ្រឿង | ៣ | ៤០-៦០គ្រឿង/គ្រួសារ | ១៨០គ្រឿង | ពេញមួយឆ្នាំ |
| លាន់ | គ្រឿង | ៦ | ២០-៤០គ្រឿង/គ្រួសារ | ២៤០គ្រឿង | វិច្ឆិកា-សីហា |
| សំណាញ់ | វង់ | ៥ | វង់/គ្រួសារ | ៥វង់ | វិច្ឆិកា-សីហា |
| ឈ្នាងជញ្ជាក់លៀស | គ្រឿង | ២០ | ១គ្រឿង/គ្រួសារ | ២០គ្រឿង | ធ្នូ-ឧសភា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ៣០គ្រឿង | ២០០-៥០០គីឡូក្រាម | ៦,៥-១៣សេះ |
| ទូកអុំ | គ្មាន | | |

គ- ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ១៨០០គីឡូក្រាម | ២៤០០គីឡូក្រាម | ៤២០០គីឡូក្រាម |
| វារីសត្វ (ខ្យង លៀស) | ៣១៥០០គីឡូក្រាម | | ៣១៥០០គីឡូក្រាម |

## ៥. ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក- ទស្សនៈវិស័យ

សហគមន៍នេសាទបឹងវាមមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ- គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលជាកន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ទំនាបលិចទឹកក្នុងរដូវតំឡើង និងនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ប្រភេទឧបករណ៍អនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| បឹងវាម | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ២០០០០ម/ ១០០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ១៥០០០ម/ ១០០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មករា-ឧសភា | អួនអូស | ២០ម៉ែត្រ/គ្រួសារ | ៦០០ម/ ៣០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | សន្ទូចរនង | ៣០០ផ្លែ/គ្រួសារ | ៣០០០០ម/ ១០០គ្រួសារ | -សមាជិកស.ន<br>មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | លប | ៥០គ្រឿង/គ្រួសារ | ២៥០គ្រឿង/ ៥០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-សីហា | លាន់ | ៥០គ្រឿង/គ្រួសារ | ២៥០គ្រឿង/ ៥០គ្រួសារ | -សមាជិកស.ន<br>មិនមែនសមាជិកស.ន |
| | វិច្ឆិកា-សីហា | សំណាញ់ | ១០វង់/គ្រួសារ | មិនកំណត់ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ធ្នូ-ឧសភា | ឈ្នាងជញ្ជាត់លៀស | ១គ្រឿង/គ្រួសារ | ៦០គ្រឿង/ ៦០គ្រួសារ | -សមាជិកស.ន<br>មិនមែនសមាជិកស:ន |

គ២-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងត្រែង (៦៤៥ ហ.ត) | ៦ហិកតា (ប=៣០០មx ទ=២០០ម) | អភិរក្សត្រីមេពូជ | បោះបង្គោលស៊ីម៉ងត៏ (7mX0.15mx0.15m) ចំនួន៥០ដើមព័ទ្ធជុំវិញកន្លែងអភិរក្សមានទំហំ ៦ហ.ត និងមានបរិមាត្រ | ៥០០០ | ១/៣/១៩ | ១/៥/២១ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | 1000ម៉ែត្រក្នុងចន្លោះ20 ម៉ែត្របោះមួយបង្គោល | | | |
| | | | ធ្វើស្លាកសញ្ញាអភិរក្ស ចំនួន៦ផ្ទាំងដាក់នៅជាប់ ព្រំប្រទល់កន្លែងអភិរក្ស | ៥០០ | ១/៤/១៩ | ១/៦/២១ |
| | | | ទម្លាក់គល់ឈើចំនួន ៣០០គល់ចូលក្នុង កន្លែងអភិរក្សត្រីមេពូជ | ៤៥០០ | ១/៣/១៩ | ១/៥/២១ |
| | | | សាងសង់ស្នាក់ការ បណ្តែតទឹកដើម្បីការពារ កន្លែងអភិរក្សត្រីមេពូជ | ២០០០ | ១/៥/១៩ | ១/៧/២១ |

គ៣-ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះ/ទីតាំង | ទំហំ (ហ.ត) | ប្រភេទកូនឈើ ដែលត្រូវការពារ និងអភិរក្ស | សកម្មភាព | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| នាទីព្រៃលិចទឹកនៅព័ទ្ធជុំវិញបឹងវាម | ៣៧ | ដើមរាំង រំដេញ ត្រស់ សណ្តាន់ ប្របួយ ភ្នំភ្លែង | កំណត់ និងបោះបង្គោលព្រំប្រទល់ នាទីព្រៃលិចទឹក ដែលត្រូវការពារ និងអភិរក្សចំនួន ៥០បង្គោល | ៥០០០ | ១/២/១៩ | ២០២១ |
| | | | ធ្វើស្លាកសញ្ញា អភិរក្សព្រៃលិច ទឹកចំនួន៨ផ្ទាំង | ៧០០ | ១/៣/១៩ | ២០២១ |
| | | | ធ្វើទិវាអភិរក្ស ដើម្បីផ្សព្វផ្សាយ អំពីគុណតម្លៃ និងការគ្រប់គ្រង ព្រៃលិចទឹក | ៣០០ | ១/២/១៩ | ២០២១ |

គ៤-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល

ផែនការល្បាតទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | គោលបំណង | អ្នកចូលរួមអនុវត្តន៍ | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ទិញទូកស្ទាច់០២គ្រឿង ប្រវែង៩ម៉ែត្រ និងម៉ាស៊ីនទូកកម្លាំង១៧សេះ | ចុះល្បាតការពារនិងទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទស.ន | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ២៥០០ | ២០១៩ | ២០២១ |
| ទិញឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត( អាវពោងសុវត្ថិភាព អាគុយ អំពូលភ្លើងហ្វា ទូរស័ព្ទវិទ្យុទាក់ទង ម៉ាស៊ីនថត ពិល អាវភ្លៀង កែវយឺត មេក្រូ ប្រេងសាំង ប្រេងម៉ាស៊ីន,...។ | ប្រើប្រាស់សម្រាប់ចុះល្បាត តាមដាន ត្រួតពិនិត្យ ទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទស.ន | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ១៥០០ | ២០១៩ | ២០២១ |
| រៀបចំក្រុមល្បាត និងបែងចែកតាមវេនចុះល្បាតប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ | ឲ្យមានក្រុម និងវេនចុះល្បាតឲ្យបានទៀងទាត់ជាប្រចាំ | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ៥០០ | ២០១៩ | ២០២១ |
| -ផ្សព្វផ្សាយតាមមេក្រូ៦ដង/ឆ្នាំ<br>-បិទលិខិតបទដ្ឋានគតិយុត្តផ្សព្វផ្សាយចំនួន២ដង/ឆ្នាំ | បង្កើនការយល់ដឹងអំពីឧបករណ៍នេសាទស្របច្បាប់ ឧបករណ៍នេសាទហាមឃាត់ និងការពារកន្លែងអភិរក្សត្រីមេពូជ | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន<br>- អាជ្ញាធរភូមិ ឃុំ | ៥០០ | ២០១៩ | ២០២១ |

គ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំឡើង ដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួនគ្រួសារ | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីក្នុងស្រះ | ៥០ | ប្រា ក្រាញ់ ទីឡាព្យា | ៤០០០០០កូនត្រី | ១/២/១៩ | ១/៦/២១ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៥០ | ត្រីអណ្តែង | ៣០០០០កូនត្រី | ១/៤/១៩ | ១/៦/២១ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៣០ | កង្កែប | ៣០០០០កូនកង្កែប | ១/៤/១៩ | ១/៩/២១ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៣០ | អន្ទង់ | ៤០០០០កូនអន្ទង់ | ១/១/១៩ | ១/១០/២១ |

គ៦-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ

ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| វគ្គបណ្តុះបណ្តាល និងទិវាអភិរក្ស | គោលបំណង | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| **ក. វគ្គបណ្តុះបណ្តាល** | | | | |
| ច្បាប់ស្តីពីជលផល អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងស.ន | បង្កើនយល់ដឹងអំពីខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលជលផល | -គណៈកម្មការ និងសមាជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| ជំនាញសម្របសម្រួល និងជំនាញដោះស្រាយទំនាស់ | មានចំណេះដឹងក្លាយជាអ្នកសម្របសម្រួល និងចេះដោះស្រាយទំនាស់បានល្អ | | ២០១៩ | ២០២១ |
| របៀបសរសេរលិខិតរដ្ឋបាល(របាយការណ៍ និងកំណត់ហេតុ) | មានចំណេះដឹងអំពីសរសេរ និងគ្រប់គ្រងលិខិតរដ្ឋបាល | | ២០១៩ | ២០២១ |
| របៀបរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងធ្វើផែនការអនុវត្តន៍សកម្មភាពគម្រោង | មានចំណេះដឹងអំពីរបៀបធ្វើផែនការសហគមន៍ និងផែនអនុវត្តន៍សកម្មភាពគម្រោង | | ២០១៩ | ២០២១ |
| របៀបសរសេរគម្រោងស្នើសុំថវិកា និងធ្វើផែនការគ្រប់គ្រងថវិកាស.ន និងរបៀបស្វែងរកថវិកា | មានចំណេះដឹងអំពីរបៀបសរសេរគម្រោងស្នើសុំថវិកា និងការធ្វើផែនការគ្រប់គ្រង និងយុទ្ធសាស្ត្រស្វែងរកថវិកា | | ២០១៩ | ២០២១ |
| - កសាងភាពជាដៃគូ និងបណ្តាញ<br>- ភាពជាអ្នកដឹកនាំ | -មានចំណេះដឹងអំពីសារៈប្រយោជន៍កសាងភាពជាដៃគូ និងបណ្តាញ<br>-ក្លាយទៅជាអ្នកដឹកនាំស.នល្អ | | ២០១៩ | ២០២១ |
| ប្រភេទនៃអ្នកចូលរួមក្នុងការអភិវឌ្ឍ | មានចំណេះដឹងអំពីការជ្រើសរើស និងធ្វើការជាមួយអ្នកចូលរួមពិតប្រាកដក្នុងការអភិវឌ្ឍសហគមន៍មូលដ្ឋាន | | ២០១៩ | ២០២១ |
| **ខ. ទិវាអភិរក្ស និងផ្សព្វផ្សាយ** | | | | |
| ការបង្កើត និងសារប្រយោជន៍នៃការគ្រប់គ្រងកន្លែងអភិរក្សត្រីមេពូជ | ឲ្យមានការចូលរួមពីសមាជិកស.ន និងពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈសំណួរ ចម្លើយ ល្បែងប្រាជ្ញាផ្សព្វផ្សាយអំពីការបង្កើត និងសារប្រយោជន៍កន្លែងអភិរក្ស | -គណៈកម្មការស.ន<br>-សមាជិកសហគមន៍នេសាទ<br>-មិនមែនសមាជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ<br>-ពលរដ្ឋទូទៅ | ២០១៩ | ២០២១ |
| គុណតម្លៃនៃព្រៃលិចទឹក និងការគ្រប់គ្រងព្រៃលិចទឹក | ឲ្យមានការចូលរួមពីសមាជិកស.ន និងពលរដ្ឋទូទៅ ដើម្បី | | ២០១៩ | ២០២១ |

| | | | | |
|---|---|---|---|---|
| | បង្កើនការយល់ដឹងតាមរយៈ សំណួរ ចម្លើយ ល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីគុណតម្លៃ និងការគ្រប់គ្រងព្រៃលិចទឹក | | | |
| ការធ្វើនេសាទប្រកបដោយនិរន្តរភាព ក្នុងកន្លែងនេសាទសហគមន៍ | ឲ្យមានការចូលរួមពីសមាជិក ស.ន និងពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈ សំណួរ ចម្លើយ ល្បែងប្រាជ្ញា ផ្សព្វផ្សាយអំពីការធ្វើនេសាទប្រកបដោយនិរន្តរភាព | | ២០១៩ | ២០២១ |
| ផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នេសាទ | ឲ្យមានការចូលរួមពីសមាជិក ស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍ | | ២០១៩ | ២០២១ |

គ៧-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | -ផ្សព្វផ្សាយអំពីភារកិច្ច និងផលប្រយោជន៍នៃការចូលជាសមាជិកស.ន<br>-រៀបចំបញ្ជីគណនេយ្យ<br>-ប្រមូលប្រាក់ភាគទានសុំចូលជាសមាជិកស.នចាស់ និងថ្មី | ១/១/១៩ | ១/១/២១ | ១២៥ | ១០០០៛/១នាក់ សមាជិកចាស់/ថ្មី អាច៥០០នាក់ រយៈពេល៣ឆ្នាំ |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយអំពីការបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ | ១/១/១៩ | ១/១/២១ | ១៥០០ | -២០០០០៛ ៖សមាជិកធ្វើនេសាទជាអាជីព<br>-៥០០០៛ ៖សមាជិកធ្វើនេសាទម្តងម្កាល<br>-១០០០៛ ៖ ចំពោះសមាជិកគាំទ្រ មិនធ្វើនេសាទ<br>- ...៛? ៖ មិនមែនជាសមាជិកស.នតែធ្វើនេសាទជាអាជីព |

| | | | | | |
|---|---|---|---|---|---|
| -ជំនួយសប្បុរសជន<br>-អង្គការនានា<br>-ជំនួយរាជរដ្ឋាភិបាល | -រៀបចំសរសេរគម្រោងស្នើសុំថវិកានិងស្វែងរកអង្គការដៃគូអភិវឌ្ឍន៍នានា<br>-យកផែនការសហគមន៍នេះសុំដាក់បញ្ចូលសមាហរកម្មក្នុងផែនការអភិវឌ្ឍន៍ឃុំ | ១/១/១៩ | ១/១/២១ | ៣៤៥០០ | ១១៥០០ដុល្លារ/ឆ្នាំ |
| | | | គម្រោងថវិកាសរុប | ៣៦១២៥$ | រយៈពេល៣ឆ្នាំ |

ឃ- ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកស្វែងថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តតាមដំណាក់កាលនិមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូអភិវឌ្ឍន៍សម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍នេសាទ
- ពង្រឹងសម្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងខាម រយៈពេល ៣ឆ្នាំ (២០១៩ដល់២០២១)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ប្រជុំពិគ្រោះយោបល់អំពីការប្រើប្រាស់ឧបករណ៍នេសាទឲ្យសមស្រប និងកំណត់ទីកន្លែងនេសាទឲ្យបានច្បាស់លាស់ | -ធ្វើនេសាទប្រកបដោយនិរន្តរភាព<br>-បង្កើនប្រាក់ចំណូលពីផលនេសាទ<br>-ធនធានជលផលកើនឡើង | ២៥០០ | -រាជរដ្ឋាភិបាលតាមរយៈ មន្ទីរកសិកម្មខេត្ត ឬរដ្ឋបាលជលផល ឬអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ២០១៩ | ២០២១ | |
| គ២-ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | បោះបង្គោលស៊ីម៉ងត៍ចំនួន៥០ដើមដាក់ព័ទ្ធជុំវិញកន្លែងអភិរក្សទំហំ៦ ហ.ត (300មX200ម) | -មានព្រំប្រទល់កន្លែងអភិរក្សត្រីមេពូជ<br>-បែងចែកបានច្បាស់លាស់រវាងកន្លែងនេសាទ និងកន្លែងអភិរក្សត្រីមេពូជ | ៥០០០ | | ១/៣/១៩ | ១/៥/២១ | |
| | ធ្វើស្លាកសញ្ញាអភិរក្សចំនួន៦ផ្ទាំងដាក់នៅជាប់បង្គោលកន្លែងអភិរក្ស | មានសញ្ញាសម្គាល់អំពីហាមឃាត់ចូលធ្វើនេសាទ និងហាមបើកបរទូកឆ្លងកាត់ខាងក្នុងកន្លែងអភិរក្សត្រីមេពូជ | ៥០០ | | ១/៤/១៩ | ១/៦/២០ | |
| | ទម្លាក់គល់ឈើចំនួន ៣០០គល់ចូលក្នុងកន្លែងអភិរក្សត្រីមេពូជ | មានជម្រកសប្បនិម្មិតត្រីមេពូជសម្រាប់រស់នៅជំលូតលាស់បន្តពូជពងកូន និងការពារមិនឲ្យលួចនេសាទ | ៤៥០០ | | ១/៣/១៩ | ១/៥/២០ | |
| | សាងសង់ស្នាក់ការបណ្តែតទឹកដើម្បីការពារកន្លែងអភិរក្សត្រីមេពូជ | មានស្នាក់ការបណ្តែតទឹកសម្រាប់យាមល្បាត ការពារមិនឲ្យចូលនេសាទក្នុងកន្លែងអភិរក្សត្រីមេពូជ និងទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ | ២០០០ | | ១/៥/១៩ | ១/៧/២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៣-ផែនការគ្រប់គ្រងព្រៃលិចទឹក | កំណត់ និងបោះបង្គោលព្រំប្រទល់នាទីព្រៃលិចទឹកដែលត្រូវការពារ និងអភិរក្សព្រៃលិចទឹកនៅជុំវិញបឹងវាមចំនួន៥០បង្គោល | មានព្រំប្រទល់កន្លែងអភិរក្សព្រៃលិចទឹកច្បាស់លាស់ | ៥០០០ | | ១/២/១៩ | ២០២១ | |
| | ធ្វើស្លាកសញ្ញាអភិរក្សចំនួន៨ផ្ទាំងសម្រាប់ការពារ និងអភិរក្សព្រៃលិចទឹកនៅនៅជុំវិញបឹងវាម | មានសញ្ញាហាមឃាត់ការកាប់ទន្រ្ទានឈូសឆាយបំផ្លាញនាទីព្រៃលិចទឹក | ៧០០ | | ១/៣/១៩ | ២០២១ | |
| | ធ្វើទិវាអភិរក្សដើម្បីផ្សព្វផ្សាយអំពីគុណតម្លៃ និងការគ្រប់គ្រងព្រៃលិចទឹក | សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋមូលដ្ឋានបានយល់ដឹងអំពីគុណតម្លៃនៃព្រៃលិចទឹក និងចូលរួមយ៉ាងសកម្មការពារ អភិរក្សព្រៃលិចទឹក។ | ៣០០ | | ១/២/១៩ | ២០២១ | |
| គ៤-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល | -ទិញទូកស្នាច់០២គ្រឿងប្រវែង៩ម៉ែត្រនិងម៉ាស៊ីនទូកមានកម្លាំង១៧សេះ<br>-ទិញឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត<br>-រៀបចំក្រុមល្បាត និងបែងចែកវេនចុះល្បាត<br>-ផ្សព្វផ្សាយតាមមេក្រូ៦ដងក្នុងមួយឆ្នាំ និងបិទលិខិតបទដ្ឋានគតិយុត្តផ្សព្វផ្សាយ២ដង/ឆ្នាំ | -មានទូកម៉ាស៊ីន និងឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត ទប់ស្កាត់បទល្មើស<br>-ប្រជានេសាទទូទៅ និងសមាជិកសហគមន៍នេសាទបានយល់ដឹងអំពីការប្រើប្រាស់ឧបករណ៍នេសាទស្របច្បាប់នៅក្នុងកន្លែងសហគមន៍នេសាទ និងបទល្មើសនេសាទថយចុះ | ៥០០០ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈពាណិជ្ជកម្មនៅក្នុងបែ ស្រះ និង និងតង់កៅស៊ូ។ | សមាជិកសហគមន៍នេសាទចំនួនប្រហែល១៥០គ្រួសារមានចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រី កង្កែប អន្ទង់ លក្ខណៈពាណិជ្ជកម្មនៅក្នុងស្រះ និងតង់កៅស៊ូ។ | ៦០០០ | | ១/៥/១៩ | ១/៥/២១ | |
| គ៦-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | -បណ្តុះបណ្តាលអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសហគមន៍នេសាទ និងពង្រឹងសមត្ថភាពគណៈកម្មការ និងសមាជិកស.ន។<br>-ធ្វើទិវាអភិរក្ស និងផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ និងលេងល្បែងប្រាជ្ញា ដែលទាក់ទងកន្លែងអភិរក្សត្រីមេពូជ ព្រៃលិចទឹក និងផលប្រយោជន៍នៃការចូលរួមក្នុងស.ន។ | - គណកម្មការ និងសមាជិកសហគមន៍បានយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសហគមន៍នេសាទ និងមានសមត្ថភាពក្លាយជាអ្នកដឹកនាំល្អ ឬជាគ្រូបង្គោលក្នុងសហគមន៍មូលដ្ឋាន<br>- សមាជិកសហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋានបានយល់ដឹងអំពីសារប្រយោជន៍នៃកន្លែងអភិរក្សត្រីមេពូជ ព្រៃលិចទឹក និងផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នេសាទ។ | ៣០០០ | -រាជរដ្ឋាភិបាលតាមរយៈ មន្ទីរកសិកម្មខេត្ត ឫរដ្ឋបាលជលផល ឫអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ២០១៩ | ២០២១ | |
| គ៧-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | -ផ្សព្វផ្សាយអំពីភារកិច្ច និងផលប្រយោជន៍នៃការចូលជាសមាជិកសហគមន៍ | ទទួលបានថវិកាទ្រទ្រង់សម្រាប់អភិ-វឌ្ឍន៍សហគមន៍តាមគម្រោងផែនការ | ៣៦១២៥ | -សមាជិក និងមិនមែនសមាជិកសហគមន៍<br>-រាជរដ្ឋាភិបាលតាមរយៈ | ១/១/១៩ | ១/១/២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -ប្រមូលការបង់ប្រាក់ភាគទានសុំចូលជាសមាជិក ស.ន និងអ្នកសុំចូលថ្មី<br>-ធ្វើគម្រោងស្នើសុំថវិកា និងស្វែងរកអង្គការដៃគូអភិវឌ្ឍន៍នានា<br>-យកផែនការនេះសុំដាក់បញ្ចូលសមាហរណកម្មក្នុងផែនការអភិវឌ្ឍន៍ឃុំ | | | មន្ទីរកសិកម្មខេត្ត ឫរដ្ឋបាលជលផល ឫអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | | | |

## តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | | | | | | | ២០២០ | | | ២០២១ | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | ... | ធ្នូ | មករា | ... | ធ្នូ |
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | |
| គ២-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | |
| គ៣-ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | |
| គ៤-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល | | | | | | | | | | | | | | | | | | |
| គ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | |
| គ៦-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| គ៧-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | |

បានឃើញ និងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ.................. ខែ............ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កំពង់ចាម ថ្ងៃទី០៥ ខែ........ឆ្នាំ២០១៨
នាយសង្កាត់រដ្ឋបាលជលផលស្រីសន្ធរ

លេខ : ២៤២៨
បានឃើញ និងឯកភាព
ថ្ងៃ.................. ខែ............ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ........ឆ្នាំ២០១៨
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
អេង ជាសាន

លេខ ........
បានឃើញ និងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលស្រីសន្ធរ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ.................. ខែ............ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ប្រាំយ៉ាម ថ្ងៃទី ០២ ខែ........ឆ្នាំ២០១៨
មេឃុំប្រាំយ៉ាម
ខៀវ_ឡុន

លេខ : ........
បានឃើញ និងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"
ថ្ងៃ.................. ខែ............ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កំពង់ចាម ថ្ងៃទី ១១ ខែ........ឆ្នាំ២០១៨
ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម

សូមគោរពជូន
លោកមេឃុំប្រាំយ៉ាម
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ.................. ខែ............ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ក្ដិច្ច ថ្ងៃទី ០២ ខែ........ឆ្នាំ២០១៨
ប្រធានគណៈកម្មការសហគមន៍នេសាទបឹងវាម

លេខ : ........
បានឃើញ និងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ.................. ខែ............ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កំពង់ចាម ថ្ងៃទី ០៥ ខែ........ឆ្នាំ២០១៨
នាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម
អ៊ុំ_ណារិន